# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ២៣ ខែ មិនា ឆ្នាំ២០១២

## ជប៉ុនផ្តល់ ៩២,២៩០ ដុល្លាអាមេរិក សម្រាប់ការបំពាក់សម្ភារៈបរិក្ខារពេទ្យក្នុង បន្ទប់វះកាត់នៃមន្ទីរពេទ្យបង្អែក

ក្រោមគ្រោងការណ៍នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរបស់ជប៉ុន ជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ(ជំនួយគូសាណូណិ) រដ្ឋាភិបាលជប៉ុននឹងផ្តល់ទឹកប្រាក់សរុបចំនួន ៩២,២៩០ដុល្លាអាមេរិក ដល់ស្រុកប្រតិបត្តិជើងព្រៃ-បាធាយសម្រាប់ការបំពាក់សម្ភារៈបរិក្ខារពេទ្យក្នុងបន្ទប់វះកាត់នៃមន្ទីរពេទ្យបង្អែកជើងព្រៃ ខេត្តកំពង់ចាម។ កិច្ចសន្យាផ្តល់ជំនួយត្រូវបានចុះហត្ថលេខាដោយលោក កាវ៉ាម្ញ៉ា ហ៊ីរ៉ូស៊ី ឧបទូតស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងលោក ហឿង ថុល ប្រធានការិយាល័យសុខាភិបាលស្រុកប្រតិបត្តិជើងព្រៃ-បាធាយ នៅស្ថានទូតជប៉ុន។



ដើម្បីបង្កើនសេវាសង្គ្រោះបន្ទាន់ និងវះកាត់ឲ្យកាន់តែប្រសើរឡើង ស្រុកប្រតិបត្តិជើងព្រៃ -បាធាយនឹងអនុវត្តគម្រោងបំពាក់សម្ភារៈបរិក្ខារពេទ្យសម្រាប់បន្ទប់វះកាត់ក្នុងមន្ទីរពេទ្យបង្អែកជើងព្រៃស្ថិតនៅក្បែរចំណុចប្រសព្វរវាងផ្លូវជាតិលេខ៦ និងផ្លូវជាតិលេខ៧ក្នុងខេត្តកំពង់ចាម។ គម្រោងនេះនឹងធ្វើឲ្យប្រជាជនប្រមាណ២០០,០០០នាក់ដែលរស់នៅក្នុងស្រុកជើងព្រៃ និងស្រុកបាធាយ ព្រមទាំងអ្នកជំងឺសង្គ្រោះបន្ទាន់ដែលមកពីតំបន់នានាអាចទទួលបានសេវាសង្គ្រោះបន្ទាន់ និងវះកាត់កាន់តែប្រសើរឡើង។

កម្មវិធីជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ ( *ជំនួយគូសាណូណិ*) របស់រដ្ឋាភិបាលជប៉ុនបានចាប់ផ្តើមតាំងពីឆ្នាំ១៩៩១ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការអភិវឌ្ឍន៍ និងស្តាបនាប្រទេសឡើងវិញនៅតាមកំរិតមូលដ្ឋាន។ គម្រោងជំនួយនេះមានទិសដៅការពារជនងាយរងគ្រោះពីកត្តាមួយចំនួនដូចជា ភាពក្រីក្រ និងភាពអកុសលដែលអាចគំរាមកំហែងដោយផ្ទាល់ដល់ជីវភាពរស់នៅ ការចិញ្ចឹមជីវិត និងសេចក្តីថ្លៃថ្នូររបស់ពួកគេ ក៏ដូចជាជួយជំរុញនូវភាពម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង៤៧លានដុល្លាអាមេរិកដល់អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាលដើម្បីអនុវត្តគម្រោងចំនួន ៤៧១គម្រោងនៅទូទាំងប្រទេស។




ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

ទូរសព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០

អ៊ីមែល: eco.jpn@.pp.mofa.go.jp

គេហទំព័រ: http://www.kh.emb-japan.go.jp